# កិច្ចព្រមព្រៀង

## ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ
## នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
## និង
## របស់សាធារណរដ្ឋសង្គមនិយមវៀតណាម

*រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា*

*និង*

*រដ្ឋាភិបាលនៃសាធសរណរដ្ឋសង្គ«និយមវៀតណាម*

*មានបំណងពង្រឹង និង ពង្រីកថែមទៀតនូវទំនាក់ទំនងពិសេសកម្ពុជា*

*វៀតណាមក្នុងស្មារតីនៃសន្ធិសញ្ញាសន្តិភាព មិត្តភាពនិង សហប្រតិបត្តិការរវាង*

*សាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋសង្គ«និយមវៀតណាម ចុះហត្ថលេខា*

*នាថ្ងៃទី ១៨ កុម្ភៈ ១៩៧៩*

*ដោយយល់ឃើញសភាពជាក់ស្តែងថា តំបន់សមុទ្រ ដែលស្ថិតនៅចន្លោះសមទ្ទនៃខេត្តកំពត និងប្រជ្ជុំកោះពូលោវៃ របស់សាធា រ ណរដ្ឋប្រជាមានិតកម្ពុជា មួយចំណែក និងឆ្នេសេមុទ្ទនៃខេត្តកៀន យ៉ាង កោះហ្វ៊ូកុក និងប្រជុំកោះថូជូរបស់សាធារណរដ្ឋសង្គម និយមវៀតណាម មួយចំណែកទៀត ប្រមូលផ្តុំតំបន់ទឹករបស់កម្ពុជា និងរបស់វៀតណាម ជាយូរលង់មកហើយតាមលក្ខ័ណ្ឌភូមិសាស្ត្រពិសេស និងសារសំខាន់យ៉ាងខ្ពស់ក្នុងកិច្ចការពារជាតិ និងសេដ្ឋកិច្ចនៃប្រទេសទាំងពីរ*

*បានព្រមព្រៀងគ្នា ដូចតទៅ*

### ប្រ កា រ ១

*តំបន់ទឹកស្ថិតនៅចន្លោះឆ្នេរសមុទ្ទនៃខេត្តកំពត ព្រមទាំងប្រជុំកោះ ពូលោវៃរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា មួយចំណែក និងឆ្នេរសមុទ្ទខេត្តកៀន យ៉ាង កោះហ្វ៊ូកុក និងប្រជុំកោះថូជូរបស់ សាធារណរដ្ឋវៀតណាម មួយ*

ចំណែក ទៀត ជាតំបន់ទឹកប្រវត្តិសាស្ត្រចំណុះក្រោមរបបច្បាប់នៃដែនដីផ្ទៃក្នុង និងមានព្រំប្រទល់កំណត់ ដូចខាងក្រោម :

"កំណត់តាម មេរីឌីយាងគ្រិនហ្វិចខាងកើត"

ផ្នែកទិសពាយ័ព្យគិតពីខ្សែត្រង់តភ្ជាប់បណ្តាចំណុចភូមិសាស្ត្រ "០៩°៥៤២ រយៈទទឹងខាងជើង ១០២°៥៥២ រយៈបណ្តោយខាងកើត" និង "០៩°៥៤៥ រយៈទទឹងខាងជើង ១០២°៥៧០ រយៈបណ្តោយខាងកើត" នៃកោះពូលោវៃ" កម្ពុជា "មកចំណុះភូមិសាស្ត្រ ១០°២៨១ រយៈទទឹងខាងជើង ១០៣°៨៤០ រយៈបណ្តោយខាងកើត" និង "១០°២៥៦ រយៈទទឹងខាងជើង ១០៣°៨៩២ រយៈបណ្តោយខាងកើត" នៃកោះសេះ " កម្ពុជា " ដល់ចំណុចភូមិសាស្ត្រ " ១០°៣០០ រយៈទទឹងខាងជើង ១០៣°៣២៨ រយបណ្តោយខាងកើត " នៃកោះថ្មី " កម្ពុជា " រហូតដល់ចំណុចភូមិសាស្ត្រ " ១០°៣២៨ រយៈទទឹងខាងជើង ១០៣°៨៨២ រយៈបណ្តោយ ខាងកើតនៃឆ្នេរសមុទ្រខេត្តកំពត "កម្ពុជា"។

ផ្នែកខាងជើងគឺឆ្នេរសមុទ្រខេត្តកំពត គិតពីចំណុចភូមិសាស្ត្រ " ១០°៣២៨ រយៈទទឹងខាងជើង ១០៣°៨៨២ រយៈបណ្តោយខាងកើត " រហូតដល់ចំណុចជាយ ព្រំដែនដីគោកវៀតណាម កម្ពុជា លើឆ្នេរសមុទ្រ។

ផ្នែកខាងអរគ្នេយ៍ គិតពីខ្សែដែលតភ្ជាប់ពីចំណុចរបស់ជាយព្រំដែនដីគោកវៀតណាមកម្ពុជា លើឆ្នេរសមុទ្ររហូតដល់ចំណុចភូមិសាស្ត្រ " ១០°០៩២ រយៈ ទទឹងខាងជើង ១០៤°០២៣ រយៈបណ្តោយខាងកកើត " ជាកោះឈ្មោះអាន អៀននៃកោះហ្វ៊ូកុក " វៀតណាម " ហើយសៀរតាមឆ្នេរកោះនេះរហូតដល់ជ្រោយកោះឈ្មោះ ឌីតដ នៅលើចំណុចភូមិសាស្ត្រ "១០°០២៨ រយៈទទឹងខាងជើង ១០៣°៥៩១ រយៈបណ្តោយខាងជើង តពីនេះរហូតមកដល់ចំណុចភូមិសាស្រ " ០៩°១៨១ រយៈទទឹងខាងជើង ១០៣°២៦៨ រយៈបណ្តោយខាងកើតនៃកោះថូជូ "វៀតណាម " រហូតមកចំណុចភូមិសាស្ត្រ " ០៩°១៥០ រយៈទទឹងខាងជើង ១០៤°២៧០ រយៈបណ្តោយខាងកើតនៃកោះបានញ៉ាននៃប្រជុំកោះថូជូ វៀតណាម។

ផ្នែកខាងទិសនិរតី គិតពីខ្សែត្រង់ទាញពីចំណុចភូមិសាស្ត្រ " ០៩°៥៥"០ រយៈទទិងខាងជើង ១០២°៥៣៥ រយៈបណោតាយខាងកើត "នៃកោះពូលោវៃ" ដល់ ចំណុច " ០៩°១៥០ រយៈទទឹងខាងជើង ១០៣°២៧០ រយៈបណ្តោយខាងកើត " នៃកោះ បានញ"ាន នៃប្រជុំកោះ ថូជូ វៀតណាម។

## ប្រការ ២

ក្នុងកាលដ៏គួរ គូភាគីនឹងចរចារ ដើម្បីកំណត់ខ័ណ្ឌសីមានៃព្រំប្រទល់សមុទ្រ រវាងប្រទេសទាំង ពីរក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ ចែងក្នុងប្រការ១ ដោយឈរ លើស្មារតី សមភាព មិត្តភាព គោរពគ្នាទៅវិញទៅមកនូវឯករាជ្យភាព

*អធិបតេយ្យភាព បូរណភាពដែនដី និងផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់របស់ភាគី និមួយៗ។*

## *ប្រការ ៣*

*ក្នុងរយៈពេលរង់ចាំដំណោះស្រាយពីព្រំដែនសមុទ្ទ រវាងរដ្ឋទាំងពីរក្នុងតំបន់ទឹកប្រវត្តិសាស្ត្រចែងក្នុងប្រការ១ : ចំណុចប្រសព្វ ០ នៃខ្សែមូលដ្ឋានទាំងពីរ ដែលសំរាប់វាស់ទទឹងដែនសមុទ្រនៃប្រទេសនិមួយៗ ស្ថិតក្នុងសមុទ្រលើខ្សែបន្ទាត់ដែលភ្ជាប់ប្រជុំកោះថូជូ និងកោះពូលោវ៉ៃ" នឹងត្រូវកំណត់ដោយកិច្ចព្រមព្រៀងនៃគូភាគី។*

*-គូភាគីបន្តចាត់!!ទុកខ្សែហៅប្រេវិយេ គូសក្នុងឆ្នាំ ១៩៣៩ ជាខ្សែបែងចែកកោះក្នុងតំបន់នេះ។*

*-គូភាគីដំណើរការ ការយាមល្បាត និងត្រួតពិនិត្យក្នុងតំបន់ទឹកប្រវត្តិសាស្ត្រនេះ។*

*-ប្រជាជនក្នុងតំបន់បន្តប្រកបរបរនេសាទនិងការយកផលជល ? សមុទ្រផ្សេងទៀតក្នុងតំបន់នះតាមទំលាប់ដែលមានមកដល់ឥឡូវ។*

*ចំណែកការធ្វើអាជីវកម្ម លើធនធានធម្មជាតិក្នុងតំបន់នេះ គូភាគីនឹងសហការសំរេចបញ្ហានេះដោយកិច្ចព្រមព្រៀង។*

*ធ្វើនៅ ហូ ជី មិញ ថ្ងៃទី ៧ ខែ កក្កដា ១៩៨២*

*ជាពីរច្បាប់ ជាភាសាវៀតណាម និង ភាសាខ្មែរ ។ អត្ថបទទាំងពីរនេះមានតម្លៃដូចគ្នា។*

| | |
|---|---|
| *ជំនួសមុខ* | *ជំនួស* |
| *រដ្ឋាភិបាលនៃសាធារណរដ្ឋ* | |
| *រដ្ឋាភិបាលនៃសាធារណរដ្ឋ* | |
| *ប្រជាមានិតកម្ពុជា* | *សង្គមនិយមវៀតណាម* |
| *ហ៊ុន-សែន* | *ង្វៀង កូថាច់* |
| *រដ្ឋមន្ត្រីការបរទេស* | *រដ្ឋមន្ត្រីការបរទេស* |

*នៃសាធសរណរដ្ឋប្រជាមានិតកម្ពុជា*

*នៃសាធារណរដ្ឋសង្គមនិយមវៀតណាម*